គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

NGO Committee on the Rights of the Child

# សៀវភៅមគ្គុទ្ទេសក៍អង្គការបំពេញការងារដើម្បីជួយកុមារ

## ប្រចាំខេត្តរតនគិរី

២០០៧

# បុព្វកថា

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល (គ.អ.ស.ក) ជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលចំនួន៤៦ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានការប្តេជ្ញាចិត្តចំបងរួមចំពោះបញ្ហាសិទ្ធិកុមារ។ គ.អ.ស.ក បង្កើតឡើងនៅឆ្នាំ ១៩៩៤ ដោយសមាជិកអង្គការចំនួន ៩ ដែលជ្រើសរើសតាមការបោះឆ្នោត ។ គ.អ.ស.ក ប្រឹងប្រែងលើកកំពស់ការយល់ដឹងស្តីពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ក្នុងចំនោមកុមារ មាតាបិតានិងស្ថាប័នពាក់ពន្ធ័ទាំងអស់ ។ អង្គការនេះធ្វើការប្រឹងប្រែង និងប្រើប្រាស់ធនធានរបស់ខ្លួនដើម្បីអោយមានការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិកុមារមានប្រសិទ្ធិភាពតាមរយៈការតស៊ូមតិសំរាប់សិទ្ធិកុមារ ។ ជាពិសេស គ.អ.ស.ក ផ្តោតទៅលើការបង្កើត និងកែប្រែច្បាប់ផ្សេងៗដែលទាក់ទងនឹងកុមារ ។ គ.អ.ស.ក ក៏តាមដានការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា និងធ្វើរបាយការណ៍បន្ថែមស្តីពីការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា ដាក់ជូនគណៈកម្មាធិកាសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ។ គ.អ.ស.ក ក៏មានទិសដៅបង្កើនសមត្ថភាពរបស់សមាជិកខ្លួនផងដែរ ។

ដើម្បីឱ្យមានភាពងាយស្រួលក្នុងការទំនាក់ទំនង ការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែមានភាពរលូន និងលើកកំពស់ការចូលរួមរបស់កុមារ គ.អ.ស.ក បានរៀបចំបង្កើតឱ្យមានសៀវភៅមគ្គុទ្ទេសក៏ក្លឹបកុមារនេះឡើង ដែលក្នុងនោះរួមមានព័តិមានស្តីពីប្រវត្តិអង្គការ ទស្សនៈវិស័យ បេសកកម្ម កម្មវិធី និងសកម្មភាពចំបងៗ តំបន់ប្រតិបត្តិការការងារ តារាងរាយនាមសមាជិក និងអាសយដ្ឋានទំនាក់ទំនងរបស់អង្គការតាមបណ្តាញខេត្ត-ក្រុងចំនួន១១ ប្រចាំឆ្នាំ ២០០៧។

គ.អ.ស.ក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមការងារនៃអង្គការតាមខេត្ត ដែលបានបំពេញការងារដើម្បីជួយកុមារ និងបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន គ.អ.ស.ក ដែលបានសហការ និងខិតខំប្រឹង ប្រែងអស់ពីកំលាំងកាយចិត្ត។ ឆ្លៀតក្នុងឱកាសនេះដែរ សូមថ្លែងអំណរគុណ និងកត្តញ្ញូតាធម៌ ចំពោះអង្គការភ្លែន អន្តរជាតិ ដែលបានឧបត្ថម្ភ ជ្រោមជ្រែងទាំងផ្នែកមូលនិធិ និងបច្ចេកទេសក្នុងការ ផលិតសៀវភៅនេះ លេចចេញជារូបរាង។

ជាទីបញ្ចប់ គ.អ.ស.ក សូមជូនពរដល់ ក្រុមការងារនៃអង្គការដែលបានបំពេញការងារដើម្បីជួយកុមារក្នុងខេត្តរតនគីរី និងបុគ្គលិកទាំងអស់របស់ គ.អ.ស.ក សូមជួបតែសេចក្តីសុខសំរេចរាល់កិច្ចការនានា និងកាន់តែមាន ភាពរឹងមាំថែម ទៀត ដើម្បីបំរើ ឱ្យផលប្រយោជន៍ដល់កុមារ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧

# អង្គការមូលនិធិគាំទ្រកុមារ (ម.គ.ក)

## ១. ប្រវត្តិអង្គការ :

មូលនិធិគាំទ្រកុមារ គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកបានបង្កើតឡើងនៅឆ្នាំ២០០១ ដោយស្ថាបនិតជាអតីតបុគ្គលិក អង្គការជាតិ អន្តរជាតិ និងក្រុមហ៊ុនឯកជន។

អង្គការមូលនិធិគាំទ្រកុមារធ្វើការ ដើម្បីបំរើផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់កុមារ ព្រមទាំង យុវជន និងសង្គម ដោយពុំមានការរើសអើង និងស្វែងរកប្រាក់ចំណេញ មិនបំរើអោយគណបក្សនយោបាយ និងមិនប្រកាន់សាសនាណាមួយឡើយ។

## ២. ទស្សនៈវិស័យ :

មូលនិធិគាំទ្រកុមារចង់ឃើញកុមារ និងយុវជននៅក្នុងប្រទេសកម្ពុជារួចផុតពីការរំភោភបំពាន និងមានសិទ្ធិគ្រប់គ្រាន់ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៏សហគមន៏ និងខ្លួនរបស់គេផ្ទាល់ទាំងក្នុងពេលបច្ចុប្បន្ន និងពេល អនាគត។

## ៣. បេសកកម្ម :

ចង់អោយកុមារ និងយុវជននៅសហគមន៏រស់នៅប្រកបដោយ សមភាព សមធមិ សន្តិភាព សុភមង្គល សុខមាលភាពល្អ និងមានសិទ្ធិគ្រប់គ្រាន់ ដោយធ្វើការជាមួយអ្នកពាក់ព័ន្ធនៅក៏រិត ថ្នាក់ជាតិ និងថ្នាក់ មូលដ្ឋាន ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយការរំលោភបំពានលើផ្លូវភេទ រាងកាយ និងកំលាំង ពលកម្ម ការជួញដូរ ការធ្វើចំណាកស្រុក ព្រមទាំងអោយពួកគេទទួលបាននូវការអប់រំ ការលើកកំពស់សិទ្ធិ និងសុខភាព ការអភិវឌ្ឍន៏ ការទប់ស្កាត់ ការការពារជៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងជំរុញអោយមានការចូលរួមកុមារ យុវជននៅក្នុងការអភិវឌ្ឍន៏សហគមន៏ និងខ្លួនរបស់គេផ្ទាល់ក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។

## ៤. កម្មវិធី និងសកម្មភាពចំបងៗ :

- កម្មវិធីចំបងៗរបស់មូលនិធិគាំទ្រកុមារ
  - កម្មវិធីទប់ស្កាត់កុមារ និងយុវជនស្ថិតក្នុងកាលៈទេសៈលំបាកពិសេស
    - ❖ គំរោងទប់ស្កាត់ពលកម្មលើកុមារ
    - ❖ គំរោងការពារកុមារលើវិស័យទេសចរណ៏
    - ❖ គំរោងទប់ស្កាត់ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងយុវវ័យ
    - ❖ គំរោងទប់ស្កាត់រំលោភផ្លូវភេទលើកុមារ និងយុវវ័យ
    - ❖ គំរោងលើកកំពស់ការផ្សព្វផ្សាយសិទ្ធិកុមារ
    - ❖ គំរោងប្រឆាំងអំពើហិង្សាលើកុមារ

❖ គំរោងបញ្ជ្រាបចំណេះដឹងយេនឌ័រទៅដល់យុវជននៅក្រិតសហគមន៍
❖ គំរោងទប់ស្កាត់ការធ្វើចំណាកស្រុក

- កម្មវិធីលើកកំពស់សុខភាពកុមារ និងយុវវ័យ

❖ គំរោងសុខភាពបន្តពូជយុវវ័យ និងជំងឺអេដស៍
❖ គំរោងសុខភាពភូមិ
❖ គំរោងកុមារ និងយុវវ័យស្ថិតក្នុងតំរូវការការពារពីការប្រើប្រាស់គ្រឿងញៀន
❖ គំរោងការពារ និងទប់ស្កាត់ជំងឺផ្តាសាយបក្សី

## ៥. តំបន់ភាគារ និងសកម្មភាពដែលត្រូវអនុវត្ត :

| កម្មវិធី/សកម្មភាពការងារ | ផ្នែក | ក្រុមគោលដៅ | តំបន់គោលដៅ | | ប្រភពថវិការ | សហការជាមួយ |
|---|---|---|---|---|---|---|
| | | | ស្រុក | ឃុំ | | |
| គំរោងទប់ស្កាត់ការរំលោភបំពានលើកុមារ | កម្មវិធីទប់ស្កាត់ កុមារ និងយុវជនស្ថិតក្នុងកាលៈទេសៈលំបាកពិ សេស (CYEDC) | កុមារជនជាតិឡាវ វៀតណាម និងកុមារជនជាតិភាគតិចនៅតាមភូមិ | បានលុង | -យក្សឡោម<br>-កាចាញ<br>- ឡាបានសៀក | ទីភ្នាក់ងារសហរដ្ឋអាមេរិក (USAID) និងអង្គការមូលនិធិអាស៊ី (TAF) | - មជ្ឈមណ្ឌលគ្រួយើង<br>- បណ្តាញការពារកុមារថ្នាក់ខេត្ត<br>- ក្លឹបកុមារភាគឥសាន |
| ទប់ស្កាត់ការជួញដូរ និងកេងប្រវ័ញ្ចលើកុមារ | កម្មវិធីទប់ស្កាត់ កុមារ និងយុវជនស្ថិតក្នុងកាលៈទេសៈលំបាកពិសេស (CYEDC) | - កុមារ<br>- យុវជន<br>- ឪពុកម្តាយកុមារ<br>- ប្រធានភូមិឃុំ<br>- ប្រជាជនទូទៅរស់នៅក្នុងសហគមន៍ | បានលុង | ឡាបានសៀក | Forum Syd | - មជ្ឈមណ្ឌលគ្រួយើង<br>- បណ្តាញការពារកុមារថ្នាក់ ខេត្ត<br>- ក្លឹបកុមារភាគឥសាន |
| | កម្មវិធី (CYEDC) | - ប៉ូលីស<br>- កងរាជអាវុធហត្ថ<br>- អង្គការជាតិ<br>- មន្ទីសង្គមកិច្ច<br>- កិច្ចការនារី<br>- អប់រំវប្បធមិ វិចិត្រសិល្បះ<br>- ព័តិមានតុលា | | -យក្សឡោម<br>-កាចាញ<br>- ឡាបានសៀក | ទីភ្នាក់ងារសហរដ្ឋអាមេរិក (USAID) និងអង្គការមូលនិធិអាស៊ី (TAF) | - មជ្ឈមណ្ឌលគ្រួយើង |

| | | | | | | |
|---|---|---|---|---|---|---|
| | | ការខេត្ត<br>- ប្រធានភូមិ ឃុំ | | | | |
| | កម្មវិធីទប់ស្កាត់ កុមារ និងយុវជនស្ថិតក្នុងកាលៈទេសៈលំបាកពិសេស (CYEDC) | យុវជន និងស្ត្រី | | -យក្សឡោម<br>-កាចាញ<br>- ឡាបានសៀក | ធនាគារពិភពលោក<br>World Bank | - មជ្ឈមណ្ឌលគ្រូយើង<br>- បណ្ដាញការពារកុមារថ្នាក់ ខេត្ត |

## ៦. សមាជិកបំរើការងារចំនួន ៣នាក់ ប្រុសចំនួន ២នាក់ ស្រីចំនួន ១នាក់ :

| ល-រ | នាមត្រកូល និងនាមខ្លួន | ភេទ | តួនាទី | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | ហ៊ាប សេរីវុធ | ប | នាយកប្រតិបត្តិ | ០១២ ២៣២ ៦១៧ |
| ២ | អ៊ុយ សុផល | ប | នាយកកម្មវិធី | ០១៦ ៩៦៧ ៤៧៦ |
| ៣ | រុំ សុខារី | ស | ប្រធានកម្មវិធី | ០៩២ ២៣៤ ៣២៧ |

## ៧. អាស័យដ្ឋានទំនាក់ទំនង :

- ឈ្មោះអ្នកទំនាក់ទំនង: **ហ៊ាប សេរីវុធ**
- តួនាទី **នាយកប្រតិបត្តិ**
- ផ្ទះលេខ ៩អា ផ្លូវលេខ ៣៦៨ សង្កាត់ បឹងកេងកង ៣ ខ័ណ្ឌ ចំការមន ខេត្តភ្នំពេញ
- លេខទូរស័ព្ទចល័ត ០១២ ២៣២ ៦១៧
- ទូរស័ព្ទ ០១១ ៩៩ ៧៧ ៧២
- E-mail: info@csfforchild.org
- Website: www.csfforchild.org

# តំបន់ប្រតិបត្តិការការងាររបស់អង្គការខេត្តរតនគីរី

| អង្គការ | ផ្នែក |
| --- | --- |

## ខេត្តរតនៈគីរី

### ស្រុកបានលុង

- CAMP
  - សិទ្ធិកុមារ
- CSF
  - លើកកំពស់ការយល់ដឹងស្តីពីការទប់ស្កាត់កុមារ និងយុវជនស្ថិតក្នុងកាលៈទេសៈលំបាកពិសេស

### មិនបានបញ្ជាក់ស្រុក

- LAC
  - ផ្នែកកុមារ
  - គំរោងការពារក្តីកុមារ
  - ច្បាប់ដីធ្លី
  - ផ្នែកមេធាវីទូទៅ

# កម្មវិធីការងាររបស់អង្គការនីមួយៗនៅខេត្តរតនគិរី

**- ផ្នែកអប់រំ :**

- អង្គការជំនួយកុមារដើម្បីការរួបរួម និងការចូលរួម (CAMP)
- អង្គការមូលនិធិគាំទ្រកុមារ (CSF)

**- ផ្នែកច្បាប់ :**

អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)